# របាយការណ៍នៃគោលការណ៍សុខភាព ២០២២
## មណ្ឌលសាលាឡុងប៊ិច (LBUSD)

## គោលដៅសុខភាពរបស់យើង

### យើងសំរេចបាននូវគោលដៅទាំងនេះហើយ៖

គោលការណ៍ណែនាំរបស់រដ្ឋាភិបាលសហព័ន្ធអំពីការផ្គត់ផ្គង់ម្ហូបអាហារ អនុវត្តលើគ្រប់ម្ហូបអាហារទាំងអស់ ដែលចែកចាយនៅលើបរិវេណសាលា ក្នុងពេលថ្ងៃរៀន។

សិស្សានុសិស្ស មានឱកាសក្នុងការធ្វើចលនារាងកាយយ៉ាសកម្មជាប្រចាំ។

មុខងារអ្នកសំរបសំរួលសុខភាពត្រូវបានបង្កើតឡើង ដើម្បីពង្រឹងនិងគាំទ្រនូវគោលដៅនៃគោលការណ៍នេះ និងសំរបសំរួលរវាងនាយកដ្ឋាននានា និង ទីតាំងសាលា។

ក្រុមប្រឹក្សាសុខភាពប្រចាំមណ្ឌល បានសំរបសំរួលនូវការវាយតម្លៃរាល់បីឆ្នាំម្តងទៅលើគោលការណ៍សុខភាព ហើយបានបង្កើតផែនការសកម្មភាពសំរាប់ឆ្នាំ ២០២២-២៥។

### យើងកំពុងតែអនុវត្តនូវកិច្ចការទាំងនេះ៖

ផ្តល់ឱកាសក្នុងការទទួលមតិយោបល់ជាច្រើនដង ទៅលើសកម្មភាពនៅតាមសាលា ពីបុគ្គលិក អ្នកគ្រប់គ្រង មាតាបិតា/អាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។

រើសបុគ្គលិកផ្នែកសុខភាពនៅតាមសហគមន៍មូលដ្ឋាន ដើម្បីចូលរួម ក្នុងក្រុមប្រឹក្សាសុខភាពប្រចាំមណ្ឌល។

ផ្តល់ការអប់រំអំពីការផ្គត់ផ្គង់ម្ហូបអាហារ ដែលរចនាឡើង ដើម្បីបង្កើតនូវជំនាញនិងចំណេះដែលសិស្សត្រូវការ ដើម្បីថែទាំការរស់នៅដែលមានសុខភាពល្អ ជាពិសេស ធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សា/អត្ថបទមេរៀនសំរាប់ថ្នាក់ទី ៧ និងស្រាវជ្រាវរកឱកាស ដើម្បីបញ្ចូលការអប់រំអំពីការផ្គត់ផ្គង់ម្ហូបអាហារ ក្នុងមុខវិជ្ជាសិក្សានៅកំរិតមធ្យមសិក្សា។

## អនុវត្តន៍តាមគោលការណ៍ផ្គត់ផ្គង់ម្ហូបអាហារ

គោលការណ៍ណែនាំរបស់រដ្ឋាភិបាលសហព័ន្ធ អំពីការផ្គត់ផ្គង់ម្ហូបអាហារ អនុវត្តលើគ្រប់ម្ហូបអាហារទាំងអស់ ដែលចែកចាយនៅលើបរិវេណសាលា ក្នុងពេលថ្ងៃរៀន។ (១០០%)

ទឹកល្អបរិសុទ្ធសំរាប់បរិភោគ គឺមានក្នុងម៉ោងទទួលទានអាហារ នៅត្រង់ឬជិតកន្លែងដែលបំរើអាហារ។ (១០០%)

អង្គការស្ថាប័នសាលាត្រូវបានជំរុញលើកទឹកចិត្ត អោយផ្តល់/ប្រើម្ហូបអាហារល្អៗ ឬវត្ថុដែលមិនមែនជាម្ហូបអាហារផ្សេងៗ ក្នុងគោលបំណងដើម្បីរៃអង្គាសថវិការ។ (១០០%)

សាលាត្រូវតែដាក់បញ្ជូនទៅកាន់ការិយាល័យ ដែលផ្តល់សេវាផ្គត់ផ្គង់ម្ហូបអាហារ នូវរបាយការណ៍អំពីម្ហូបអាហារដែលលក់អោយសិស្សានុសិស្ស តាមរយៈហាងដែលសិស្សធ្វើការ ម៉ាស៊ីនលក់អាហារ/ភេសជ្ជៈដោយស្វ័យប្រវត្តិ (vending machines) និងកន្លែងផ្សេងៗដទៃទៀត ដើម្បីបញ្ជាក់ថា ម្ហូបអាហារនិងភេសជ្ជៈគឺត្រូវបានអនុវត្តតាម ឬលើសពីស្តង់ដានានារបស់រដ្ឋ និងរដ្ឋាភិបាលសហព័ន្ធ ទៅទៀត។ (៨៣%)

## ដាក់ផែនការ តាមដាន និងចែករំលែក

ក្រុមប្រឹក្សាសុខភាពជួបប្រជុំទូទាំងឆ្នាំសិក្សា ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសំរេចរួម ចំពោះការវាយតម្លៃរាល់បីឆ្នាំម្តងទៅលើ មាតិការនៃគោលការណ៍សុខភាពឆ្នាំ ២០២០ ទំហំនៃការអនុវត្តតាមគោលការណ៍នៅតាមទីតាំងសាលា ការរីកចំរើនដែលមាន ចំពោះគោលដៅនៃគោលការណ៍ និងការអភិវឌ្ឍនូវផែនការសកម្មភាពថ្មី។

ក្រុមប្រឹក្សាសុខភាព រួមបញ្ចូលលោកគ្រូ អ្នកគ្រូ អ្នកគ្រប់គ្រង បុគ្គលិកទូទៅ មាតាបិតា និងសមាជិកគណៈកម្មការអប់រំ។ សិស្សានុសិស្សជាង ១២០ នាក់ មកពីអនុវិទ្យាល័យនិងវិទ្យាល័យ បានផ្តល់នូវមតិយោបល់។

លទ្ធផលនៃការវាយតម្លៃរាល់បីឆ្នាំម្តង ទៅលើគោការណ៍សុខភាព គោលការណ៍របស់គណៈកម្មការអប់រំដែលត្រូវបានកែលំអ និងផែនការសកម្មភាពសំរាប់គោលការណ៍សុខភាពប្រចាំមណ្ឌល សំរាប់ឆ្នាំ ២០២២-២៥ គឺមានដាក់ជូននៅលើគេហទំព័ររបស់មណ្ឌល (ក្នុងតារាងតាមលំដាប់អក្សរ ដោយចុចលើ W–Wellness-សុខភាព)។

បច្ចុប្បន្នភាពប្រចាំឆ្នាំមួយ នឹងមានដាក់ជូនសាធារណៈជនមើលនៅលើគេហទំព័ររបស់មណ្ឌល និងគេហទំព័ររបស់សាលានីមួយៗ។